Notice
Can't identify browser version. Agent: Mozilla/5.0 (Macintosh; Intel Mac OS X) AppleWebKit/534.34 (KHTML, like Gecko) Qt/4.8.7 Safari/534.34

# បច្ចុប្បន្នភាពនៃជំងឺកូវីដថ្មី COVID-19 នៅប្រទេសកម្ពុជា

សំរាប់ព័ត៌មានលំអិត សូមចុចមកលេខ 115

**BREAKING NEWS**

រកឃើញ ស្ត្រីជនជាតិអង់គ្លេសម្នាក់ទៀត ផ្ទុកមេរោគ **COVID-19** នៅខេត្តកំពង់ចាម



បច្ចុប្បន្នភាព ម៉ោង ៨:៣០នាទីយប់ ថ្ងៃទី១០ មីនា ២០២០ :
ប្រទេសយើងបានរកឃើញករណីជំងឺCOVID-19 សរុបចំនួន៣ករណី
- ១ករណី ជនជាតិចិន ភេទប្រុស អាយុ៦០ឆ្នាំ ជាសះស្បើយ
- ១ករណី ជនជាតិខ្មែរ ភេទប្រុស អាយុ៣៨ឆ្នាំ កំពុងដាក់ព្យាបាលនៅមន្ទីរពេទ្យបង្អែកខេត្តសៀមរាប គាត់មានសុខភាពល្អ មិនមានរោគសញ្ញាអ្វីទេ តែគាត់បន្តវិជ្ជមាន COVID-19
- ១ករណី ជនជាតិអង់គ្លេស ភេទស្រី អាយុ៦៥ឆ្នាំ កំពុងដាក់ព្យាបាលនៅមន្ទីរពេទ្យបង្អែកខេត្តកំពង់ចាម គាត់មានសុខភាពល្អ
មិនមានរោគសញ្ញាអ្វីគួរឲ្យកត់សំគាល់ទេ ។ អ្នកប៉ះពាល់ទាំងអស់នឹងយកវត្ថុវិភាគ ដាក់ឲ្យនៅដោយឡែក និងតាមដានសុខភាពចំនួន១៤ថ្ងៃ ។
នេះជាករណីនាំចូលពីប្រទេសពីប្រទេសក្រៅ ។
ប្រទេសកម្ពុជាយើងមិនទាន់រកឃើញភស្តុតាងបញ្ជាក់ថាមានការឆ្លងនៅក្នុងសហគមន៍នៅឡើយទេ ។
ទូទាំងប្រទេសយើងបានធ្វើតេស្តសរុបទាំងអស់ចំនួន ៤៨២ករណី
ព័ត៌មានបន្ថែមសូមទាក់ទងលេខ ១១៥

> Read more: បច្ចុប្បន្នភាពនៃជំងឺកូរូណាថ្មី COVID-19 នៅប្រទេសកម្ពុជា

# មានការផ្សព្វផ្សាយ តាមបណ្តាញសង្គម អំពីគ្រូពេទ្យខ្មែរម្នាក់ ត្រូវបានដាក់ឲ្យនៅដោយឡែក នៅមន្ទីរពេទ្យមួយនៅទីក្រុងហាណូយ

***Date: 10/March/2020***

តាមព័ត៌មានដែលទទួលបាន ជាភាសាអង់គ្លេស៖ “He is Cambodian doctor working in Vietnam ( Hanoi), his specialist in ENT, he treated patient confirmed with COVID-19 .he is Quaratin at hospital in HN “
បកប្រែខ្មែរ៖ គាត់ជាវេជ្ជបណ្ឌិតខ្មែរ បំរើការងារនៅវៀតណាម (ហាណូយ) គាត់មានឯកទេសខាងជំងឺ ត្រចៀក ច្រមុះ បំពង់ក គាត់បានព្យាបាលអ្នកជំងឺ ដែលបានបញ្ជាក់ថាមានវិជ្ជមាន COVID-19 គាត់តំរូវឲ្យដាក់ដោយឡែក នៅមន្ទីរពេទ្យទីក្រុងហាណូយ ។ ដូច្នេះគាត់មិនមែនជាគ្រូពេទ្យ បំរើការងារនៅពេទ្យស្រុកខ្មែរ និងរស់នៅស្រុកខ្មែរទេ ហើយគាត់ពេលនេះមិនមានវិជ្ជមាន COVID-19 ទេ គាត់គ្រាន់តែត្រូវបាន ដាក់ឲ្យនៅដោយឡែកប៉ុណ្ណោះ ។
ព័ត៌មានបន្ថែមសូមទាក់ទងលេខ ១១៥

 

# មេរោគកូរ៉ូណាវីរុសប្រភេទថ្មី ឆ្លងតាមរយៈដំណក់ទឹកតូចៗ ដែលខ្ទាតចេញមកក្រៅ តាមរយៈការក្អកឬកណ្តាស់

***Date: 08/March/2020***





មេរោគកូរ៉ូណាវីរុសប្រភេទថ្មី ឆ្លងតាមរយៈដំណក់ទឹកតូចៗ ដែលខ្ចាតចេញមកក្រៅតាមរយៈក្អកឬកណ្តាស (មិនមែនហោះហើរក្នុងខ្យល់ទេ) ។ ត្រូវចងចាំថា ដំណក់ទឹកតូចៗអ្នកជំងឺដល់ទីណា មេរោគនឹងទៅដល់ទីនោះ ។ អ្នកវិទ្យាសាស្ត្ររកឃើញថា ចំងាយខ្ចាតចេញពីមុខមនុស្សយើងចំងាយបាន ៣ហ្វីត បើគិតពីរង្វាស់ម៉ែត្រគឺ ៩០សង់ទីម៉ែត្រ ។ ដូច្នេះបើយើងនៅឆ្ងាយពីអ្នកជំងឺលើសពី១ម៉ែត្រ យើងនឹងគេចផុតពីដំណក់ទឹកតូចៗទាំងនោះ ។
ពេលអ្នកជំងឺក្អកឬកណ្តាសម្តងៗ បណ្តាលឱ្យខ្ចាតទៅលើផ្ទៃផ្សេងៗ ដូចជាលើតុ លើជញ្ជាំង លើបង្កាន់ដៃ ។ ល។ និងដៃរបស់គាត់ក្រោយញើច្រមុះប្រលាក់សំបោរ ប៉ះដៃទ្វារប៉ះជញ្ជាំងប៉ះបង្កាន់ដៃ ដែលអ្នកជាប៉ះផ្ទៃទាំងនោះបណ្តាលឱ្យឆ្លងពេលយើងប៉ះមុខនិងច្រមុះ ។ អ្នកវិទ្យាសាស្ត្ររកឃើញថា ក្នុងមួយថ្ងៃមនុស្សយើងប៉ះមុខជាមធ្យម ៦០ដង ។ ហេតុដូច្នេះ តំរូវឱ្យអ្នកជំងឺត្រូវពាក់ម៉ាស់ដើម្បីកុំឱ្យខ្ចាតចេញមកក្រៅ
នឹងទាំងអ្នកឈឺនិងអ្នកជាត្រូវតែឧស្សាហ៍លាងដៃជាមួយសាប៊ូ អាល់កុល ជេល ជាដើម ។ ចំពោះអ្នកជាពុំចាំបាច់ពាក់ម៉ាស់ទេ គឺយើងពាក់ម៉ាស់នៅពេលចាំបាច់ដូចជា កន្លែងប្រមូលផ្តុំ សួរសុខទុក្ខអ្នកជំងឺ និងក្រុមគ្រូពេទ្យ ហើយគ្រវាត់ម៉ាស់ក្នុងធុងសំរាមភ្លាមក្រោយប្រើប្រាស់ ។
ពត៌មានបន្ថែមសូមទាក់ទងលេខ ១១៥

## រដ្ឋមិនគិតថ្លៃសេវា ចំពោះការធ្វើតេស្តរកមេរោគ COVID-19 ពីអ្នកដែលត្រូវបានគេសង្ស័យថាឆ្លង COVID-19 និងចំពោះការព្យាបាលអ្នកជំងឺ ដែលមានវិជ្ជមាន COVID-19

***Date: 08/March/2020***




បើបងប្អូនសាធារណៈជន មានរោគសញ្ញាក្តៅខ្លួន ឬមានរោគសញ្ញាផ្លូវដង្ហើម និងទើបធ្វើដំណើរពីប្រទេស ដែលមានឆ្លងជំងឺ COVID-19 ឬប៉ះពាល់ជាមួយអ្នកមានជំងឺ ដែលបង្កឡើងដោយមេរោគ COVID-19 ក្នុងកំឡុងពេល១៤ថ្ងៃ មុនចេញរោគសញ្ញា សូមអញ្ជើញទៅពិគ្រោះជំងឺ នៅមន្ទីរពេទ្យខ្មែរ-សូវៀតនៅភ្នំពេញ និងនៅគ្រប់មន្ទីរពេទ្យខេត្ត នៅតាមបណ្តាខេត្តទាំងអស់នៅទូទាំងប្រទេស ។ ក្នុងករណីគ្រូពេទ្យពិនិត្យឃើញថា ចូលករណីសង្ស័យដែលតំរូវឱ្យយកវត្ថុ ឬតំរូវឱ្យសំរាកពេទ្យ អ្នកជំងឺទាំងនោះ នឹងមិនតរូវអោយមានការបង់ថ្លៃ សំរាប់ធ្វើតេស្តរកមេរោគ COVID-19 ឬ បង់ថ្លៃព្យាបាលជំងឺ ដែលបញ្ជាក់ថាមានវិជ្ជមាន COVID-19 នោះទេ ។
ការអនុវត្តន៍នេះ នឹងធ្វើឡើងទាំងជនជាតិខ្មែរ និងជនជាតិបរទេសទាំងអស់ ។
ពត៌មានបន្ថែមសូមទាក់ទងលេខ ១១៥

## Posters: វិធានការបង្ការការចំលងមេរោគ COVID-19

***Date: 07/March/2020***




- វីដេអូអប់រំខ្លី ដែលបង្ហាញពីសារៈសំខាន់ នៃការលាងដៃ ដើម្បីបង្ការជំងឺឆ្លងនានា ក្នុងនោះរួមទាំងមេរោគ COVID-19
- ករណី ជនជាតិជប៉ុនម្នាក់ មានផ្ទុកមេរោគ Covid-19
- រហូតមកដល់ពេលនេះ មិនមានរកឃើញករណីថ្មី នៃអ្នកកើតជំងឺកូរ៉ូណា ឬ COVID-19 នោះទេ នៅប្រទេសកម្ពុជា
- សេចក្តីប្រកាសព័ត៌មាន របស់ក្រសួងសុខាភិបាល ស្តីពី វិធានការឆ្លើយតប ការការពារ និងការត្រៀមអន្តរាគមន៍ លើការចំលងជំងឺកូវីត១៩ (COVID-19) និងជំងឺឆ្លងផ្សេងៗ នៅក្នុងព្រះរាជាណាចក្រកម្ពុជា

Page 1 of 61

Home

Press Release
- Avian Influenza
- SARS
- Severe Watery Diarrhea
- Swine Influenza
- Other Disease
- MERS

- Bulletins
  - Year 9 (2012)
  - Year 8 (2011)
  - Year 7 (2010)
  - Year 6 (2009)
  - Monthly respiratory buttletin
    - Year 2014
    - Year 2015
    - Year 2016
    - Year 2017
- IEC material and documents
  - Posters
  - Booklets
  - Radio Spot
  - TV Spots
  - Leaflet
  - National Guideline, Policy, and Strategy
- Applied epidemiology training
  - Course detail
  - Team and advisory board
  - First cohort (2011)
  - Second cohort (2012)
  - Documents and forms
- Collaborative Projects with Hopital Service

## Latest Articles

- បច្ចុប្បន្នភាពនៃជំងឺកូវីដ COVID-19 នៅប្រទេសកម្ពុជា
- មានការផ្សព្វផ្សាយ តាមបណ្តាញសង្គម អំពីគ្រូពេទ្យខ្មែរម្នាក់ ត្រូវបានដាក់ឲ្យនៅដោយឡែក នៅមន្ទីរពេទ្យមួយនៅទីក្រុងហាណូយ
- មេរោគកូរ៉ូណាវីរុសប្រភេទថ្មី ឆ្លងតាមរយៈដំណក់ទឹកតូចៗ ដែលខ្ទាតចេញមកក្រៅ តាមរយៈការក្អកឬកណ្តាស់
- រដ្ឋមិនគិតថ្លៃសេវា ចំពោះការធ្វើតេស្តរកមេរោគ COVID-19 ពីអ្នកដែលត្រូវបានគេសង្ស័យថាឆ្លង COVID-19 និងចំពោះការព្យាបាលអ្នកជំងឺ ដែលមានវិជ្ជមាន COVID-19
- Posters: វិធានការបង្ការការចំលងមេរោគ COVID-19

## Login Form

User Name

Password

☐ Remember Me

Log in

Forgot your username?
Forgot your password?

## Visitors Counter

| | |
|---|---|
| Today | 753 |
| Yesterday | 1326 |
| This week | 3152 |
| This month | 11546 |
| Total | 943939 |

Powered by CoalaWeb

© 2020 CDC Department Website